ពិភពរឿងនិទាន

*The World of Stories*

Reading Book

# រឿង កូនចាំផ្ទះម្នាក់ឯង

# Son Stays At Home Alone



M.60

សង្គ្រោះអ្នកញៀនគ្រឿងញៀន គឺជួយដោះស្រាយវិបត្តិសង្គម

## គោលបំណង

រឿង "កូនចាំផ្ទះម្នាក់ឯង" មានបំណងអប់រំដល់ប្អូនៗកុមារឱ្យមានចិត្តក្លាហាន ឧស្សាហ៍ព្យាយាម។ ជាងនេះទៅទៀត រឿងនេះជួយឱ្យប្អូនចេះតាំងចិត្ត និង ចេះសំរេចចិត្តក្នុងការដោះស្រាយបញ្ហានៅពេលដែលយើងកំពុងនៅតែម្នាក់ឯង។

## Objective

The tale, "Son Stays At Home Alone," is intended to educate children to be brave and industrious. The tale, in addition, helps children to be more committed and smart in making decision to deal with any problems they encounter when being left alone.





នេះជាលើកទី១ហើយដែល **ចែម** នៅផ្ទះតែម្នាក់ឯង។  ពុក និង ម៉ែ **ចែម** មិនដែលចាកចេញពីផ្ទះ ដោយទុកឱ្យកូននៅផ្ទះតែម្នាក់ឯងនោះទេ។  ប៉ុន្តែម្តងនេះពួកគាត់មានការជាបន្ទាន់  ដោយជីដូនរបស់ **ចែម** មានជម្ងឺជាទំងន់នៅឯស្រុក។  ជាថ្ងៃដែល **ចែម** ត្រៀមប្រឡងទៀត។  ដូចនេះពួកគាត់ត្រូវបង្ខំចិត្តឱ្យ **ចែម** នៅផ្ទះតែម្នាក់ឯងមួយយប់សិន។

This is the 1st time when Chem stayed at home alone. Chem's parents had never left him alone at home in such situation. They had to leave their home promptly as Chem's grandmother was seriously sick then. Besides, Chem would have an exam next day. That's why they had to leave Chem alone at home for that night.





នៅផ្ទះម្នាក់ឯង **ចែម** រវល់ណាស់ខុសប្លែកពីពេលដែលគេរស់នៅជាមួយឪពុកម្តាយ។ **ចែម** មើលមេរៀនត្រៀមប្រឡងនាព្រឹកស្អែករហូតចេះចាំអស់។ **ចែម** មានអារម្មណ៍ល្វើយណាស់ តែគេត្រូវធ្វើម្ហូប លាងចាន រៀបចំផ្ទះទៀត **ចែម** មិនហ៊ានសម្រាកនោះទេ ព្រោះខ្លាចពុកម៉ែមកវិញបន្ទោស។

Being alone at home, Chem was very busier compared to when he was with his parents. Chem learnt his lessons by heart in preparation for his exam in the next morning. He felt so tired, yet he had to do cooking, washing dishes and cleaning house. He worked incessantly, for he was afraid of being blamed by his parents.





បន្ទាប់ពីអាហារពេលល្ងាចរួច មេឃងងឹតទៅហើយ **ចែម** មានអារម្មណ៍ខ្លាចណាស់។ តែបំណាច់ដែលគេប្រាប់ពុកនិងម៉ែថាអាចនៅផ្ទះម្នាក់ឯងបាននោះ ក៏ត្រូវបាត់អស់រលីង។ **ចែម** គិតថា "យប់នេះអញគួរអុតចង្កៀងបំភ្លឺទល់ភ្លឺហើយ អញខ្លាចណាស់"។ **ចែម** ចូលក្នុងមុងដេកដោយមិនពន្លត់ចង្កៀង។

Finishing his dinner, he started to have an anxious feeling as the sky became dark. His scare disappeared, nonetheless, when he remembered what he told his parents that he could stay at home alone. "I must keep the lamp illuminating for the whole night; otherwise, I would feel afraid," he thought. He went to bed, keeping the light on.





**ចែម** ដេកមិនលក់សោះ ព្រោះគេមិនទម្លាប់មានពន្លឺចង្កៀង។ បន្ទាប់មកវាក៏ពន្លត់ចង្កៀងភ្លឹប។ ភាពងងឹតធ្វើឱ្យ **ចែម** កាន់តែខ្លាច គេងាករកទ្វារ ងាករកបង្អួច ឃើញស្រមោលដើមឈើបក់រវិចៗ **ចែម** ភ័យណាស់។ **ចែម** សួរខ្លួនឯងថា "តើអញគួរធ្វើដូចម្ដេច?។ មិនបានទេ អញត្រូវតែក្លាហានឡើង នោះគ្រាន់តែជាស្រមោលដើមឈើប៉ុណ្ណោះ"។

Chem could not sleep as he was not accustomed to sleeping under light. He switched it off then. The darkness was frightening him, when he looked through the door and windows, seeing shadows of trees waving in wind. "How should I do? No, I have to be brave. That's only the tree shadows".





បន្ទាប់ពី **ចែម** តាំងចិត្តជាអ្នកក្លាហាន រួចហើយគេក៏សំងំដេកទៅ។ កំពុងតែលង់លក់នាពេលកណ្ដាលអាធ្រាត្រ **ចែម** ភ្ញាក់ព្រើត ព្រោះឮសម្លេងមាន់ស្រែកនៅក្នុងទ្រុង។ **ចែម** និយាយតិចៗថា "អ៊ូស ! អញភ្លេចចាក់សោរទ្រុងមាន់ វីវរហើយ បើពុកម៉ែដឹងបន្ទោសអញស្លាប់ហើយ"។

Chem tried to sleep again after having committed himself to be brave. Falling asleep during that midnight, Chem was awakened when he heard his chickens yelling in their cage. Chem spoke to himself in a low voice, “Oh! I forgot to lock the chicken cage. If my parents knew, they would blame me bluntly.”





**ចែម** អុចចង្កៀងចុះទៅក្រោមជាមួយនឹងសោរដើម្បីចាក់ទ្រុងមាន់។ ដើរជិតដល់ទ្រុងមាន់គេក៏ឮសម្លេងបុរសពីរនាក់នៅក្នុងទ្រុង **ចែម** ក៏ពន្លត់ចង្កៀងភ្លឺប។ បុរសទាំងពីរកំពុងបំភ្លឺកូនពិលលួចចាប់មាន់។ **ចែម** ឃើញដូចនេះគិតថា "អញគួរធ្វើយ៉ាងម៉េចទៅ? បើអញស្រែក ចោរនេះនឹងរត់បាត់"។

Chem illuminated the lamp and went down with the key to lock the cage. Approaching the cage, he saw two men with a small flashlight in their attempt to steal his chicken, and he blew out the lamp. He was thinking then that, "What should I do? If I shouted, the thieves would escape."





**ចែម** ឃើញទ្រុងមាន់ចំហរគេក៏ដើរលបៗ ទាញទ្វារឃើតៗដើម្បីចាក់សោរក្នុងបំណងឱ្យ ចោរទាំងពីរជាប់ក្នុងទ្រុងមាន់នោះ។ **ចែម** ភ័យណាស់តែគេតាំងចិត្ត "អញត្រូវតែក្លាហាន"។

Seeing the cage door was open, he moved slowly toward the door, pulling and locking it so as to get the thieves confined. He was afraid then, but he determined that, "I must be brave."





**ចែម** ចាក់សោរហើយក៏រត់មកក្រៅ ស្រែកខ្លាំងៗ "ជួយផងៗ ចោរលួចមាន់ ជួយផង ចោរ..."។ អ្នកជិតខាងឮដូច្នេះក៏នាំគ្នារត់មកស្រូ ខ្លះកាន់ដំបង ខ្លះកាន់កាំបិត ខ្លះកាន់ពូថៅដើម្បីជួយ **ចែម** ។ ចោរទាំងពីរដែលនៅក្នុងទ្រុងមាន់ឮសម្លេងរបស់ **ចែម** ស្រែកភ័យណាស់ ខំស្ទុះរត់ចេញមកក្រៅ តែឥតប្រយោជន៍ឡើយ ព្រោះទ្វារជាប់សោរយ៉ាងមាំ។

Chem locked the door, and ran to call for helps loudly, "Helps! Helps! Helps! There are chicken thieves! Helps!" Hearing so, his neighbors ran in groups toward the scene with sticks, knives and axes to help Chem. The thieves were so anxious when they heard Chem's shouting. They tried to escape but failed as the cage was firmly locked.





អ្នកភូមិរួមទាំងលោកមេភូមិផង បានចាប់ចោរនោះយកទៅទទួលទោសតាមច្បាប់។ ពួកគាត់សប្បាយចិត្តណាស់ ព្រោះគាត់តាមរកមុខសញ្ញាចោរនេះយូរណាស់មកហើយ តែចាប់មិនដែលបានសោះ។ លោកមេភូមិសរសើរ **ចែម** ថា "ក្មួយពិតជាឆ្លាតហើយក្លាហានណាស់"។

The villagers and their chief arrested the thieves and sent them to be punished under the laws. They all were so happy because they had tried to arrest them for ages. The village chief praised Chem, "You're a very smart and brave child."



ស្អែកឡើង**ចែម** បានក្រោកពីព្រលឹមដើម្បីរំលឹកមេរៀន មុនពេលទៅសាលា។ ការប្រឡងមកដល់**ចែម**បានសរសេរ ចម្លើយយ៉ាងល្អគ្រប់សំណួរទាំងអស់។ ពេល **ចែម** ត្រឡប់ មកផ្ទះវិញក៏ឃើញពុកម៉ែនិងអ្នកភូមិជុំគ្នា **ចែម**សប្បាយ ចិត្តណាស់ហើយនិយាយទៅកាន់ពុកនិងម៉ែវាថា "ថ្ងៃនេះ កូនប្រឡងបានពិន្ទុល្អណាស់"។

**ចប់**



Chem got up in early morning to review his lessons before leaving for school. During the exam, Chem could answer all questions correctly. When he returned to his house, he saw his parents and villagers were in a meeting. He was very thrilled and told his parents that, "Today I got good scores from my exam."

**The End**

## សំណួរ

១- ហេតុអ្វីបានជា**ចែម**នៅផ្ទះតែម្នាក់ឯង?

២- **ចែម**ធ្វើការអ្វីខ្លះនៅពេលនៅផ្ទះតែម្នាក់ឯង?

៣- នៅពេលយប់តើមានរឿងអ្វីកើតឡើងនៅផ្ទះរបស់**ចែម**?

៤- តើ**ចែម**ធ្វើដូចម្ដេចនៅពេលដែលវាដឹងថា ចោរកំពុងលួចមាន់?

៥- តើ**ចែម**ប្រើវិធីបែបណា ទើបអាចចាប់ចោរទាំងពីរនាក់នោះបាន?

## Questions:

1- Why did Chem stay at home alone?

2- What Chem had done once being alone at home?

3- What happened at Chem's home during the midnight?

4- How did Chem react when he knew thieves were trying to steal his chickens?

5- What did Chem do to get the two thieves arrested?